65/7

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ២០៦
ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣
សាលដីកា
លេខ : ១៤១ "ង"
ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៤

## សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៤។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោក ជាចៅក្រម

**ក្រឡាបញ្ជី**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទៈ**លោក [redacted] ឈួន (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៤៨ឆ្នាំ ជាតិខ្មែរ ប្រពន្ធឈ្មោះ [redacted] ខេន មានទី លំនៅសព្វថ្ងៃភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង។

**មេធាវី :** លោកស្រី [redacted] តំណាងដោយអាណត្តិ

**ចុងចម្លើយៈ**លោក [redacted] សារ៉េត (ចុងបណ្តឹងសាទុក្ខ) អាយុ ៤៨ឆ្នាំ ជាតិខ្មែរ ប្រពន្ធឈ្មោះ [redacted] សុខឿន មានទីលំនៅសព្វថ្ងៃភូមិ អណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបទុមសាគរ ខេត្តកោះកុង។

**<u>អំពីវិវាទ :</u>** ប្តឹងទាមទារសុំអោយតុលាការចេញសាលក្រមដូចខាងក្រោម :



Scanned with CamScanner

-ទាមទារដីភូមិទំហំ ២០ម គុណ ៣០០ម មានទីតាំងនៅភូមិវាលរបងក្រោមឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ។

-ទាមទារដីចំការទំហំ២០ម គុណ ៣០០ម មានទីតាំងនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ។

-ទាមទារដីស្រែប្រាំងទំហំ ២១ម គុណ ២៧០ម មានទីតាំងនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ។

-ទាមទារដីចំការទំហំ ០៨ម គុណ ៧០០ម មានទីតាំងនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ។

**<u>បណ្តឹងតប</u> : សុំទាមទារដីដូចខាងក្រោម :**

-ទី ១ ដីប្រាំងមានទំហំ ១៩.៩០ម គុណ ៤០០ម មានព្រំប្រទល់

+ខាងកើតទល់ទទឹក-

+ខាងលិចទល់នឹងដីឈ្មោះ [redacted] ហោ

+ខាងជើងទល់ដីឈ្មោះ [redacted] យ៉ាន់

+ខាងត្បូងទល់ដីឈ្មោះ [redacted] សាឯម

-ទី ២ ដីចំការ(ដីឡូត៍) មានទំហំ ០៨ម គុណ ៧០០ម មានព្រំប្រទល់

+ខាងកើតទល់នឹងផ្លូវរទេះភ្លើង

+ខាងលិចទល់នឹងផ្លូវរទេះ

+ខាងជើងទល់ដីឈ្មោះ ដីឈ្មោះ [redacted] សន

+ខាងត្បូងទល់ដីឈ្មោះ [redacted] សាឯម

-ទី ៣ ដីភូមិ និង ដីចំការមានទំហំ ២០ម គុណ ៥០០ម មានព្រំប្រទល់

+ខាងកើតទល់នឹងទន្លេ

+ខាងកើតទល់នឹងដីប្រាំង

+ខាងជើងទល់ដីឈ្មោះ [redacted] ថាវី

+ខាងត្បូងទល់ដីឈ្មោះ [redacted] ហួយ

ដីទាំងបីកន្លែងស្ថិតនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ។



Scanned with CamScanner

## <u>អំពីអង្គហេតុ និង ចំណុចវិវាទ:</u>

ក-<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:</u>

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ របស់ឈ្មោ[redacted] ឈួន និង ប្រពន្ធឈ្មោះ[redacted] ខេន ដើមចោទប្តឹងថា ខ្លួន និង ប្រពន្ធបានរស់នៅលើដីភូមិ ដីចំការ និង ដីប្រាំង ដែលមានទីតាំង និង ទំហំដូចមានក្នុងកម្មវត្ថុបណ្តឹងតាំងពីឆ្នាំ ១៩៨៤ ពុំដែលមានទំនាស់ និង ពុំមាននរណាមកអះអាងថា ដីនេះជារបស់អ្នកណាទេ ហើយចេះតែរស់នៅលើដីភូមិ និងធ្វើស្រែចំការតរៀង១មក។ ទើបតែនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ មានសេចក្តីជូនដំណឹងរបស់លោកមេឃុំអង្គរអង្គស្ទីទីឈ្មោះ[redacted]ហួន បានជូនដំណឹងដល់ខ្លួន និង ប្រពន្ធអោយរុះរើ ឬសែងផ្ទះចេញពីដីរបស់ឈ្មោះ [redacted]សារ៉េត និង ប្រពន្ធឈ្មោះ [redacted]សុខឿន ចាប់ពីថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២ ជាកំណត់ ដើម្បីអោយម្ចាស់កម្មសិទ្ធិចូលមកគ្រប់គ្រងលើទ្រព្យសម្បត្តិ និង ចំពោះដើមឈើក៏ត្រូវគាស់ ឬត្រូវកាប់ចេញផងដែរ ធ្វើអោយរូបខ្លួន និង ប្រពន្ធ ព្រមទាំងក្រុមគ្រួសារទាំងមូលភ្ញាក់ផ្អើល។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៦"ក"រ.វ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់សាលាដំបូងខេត្តព្រៃវែង សំរេច :

១-ច្រានចោលការទាមទារចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៣ របស់ឈ្មោះ ញឹក ឈួន ប្រពន្ធឈ្មោះ នៅ ខេន ចាប់ពីសាលក្រមចូលជាស្ថាពរតទៅ។

២-ប្រគល់ដីដូចខាងក្រោម :

-ទី ១ ដីប្រាំងមានទំហំ ១៩,៥០ម គុណ ៤០០ម មានព្រំប្រទល់

+ខាងកើតទល់ទទឹក

+ខាងលិចទល់នឹងដីឈ្មោះ [redacted]ហោ

+ខាងជើងទល់ដីឈ្មោះ[redacted] យ៉ាន់

+ខាងត្បូងទល់ដីឈ្មោះ [redacted] សាឯម

-ទី ២ ដីចំការ(ដីឡូតិ៍) មានទំហំ ០៨ម គុណ ៧០០ម មានព្រំប្រទល់

+ខាងកើតទល់នឹងផ្លូវរទេះភ្លើង

+ខាងលិចទល់នឹងផ្លូវរទេះ

+ខាងជើងទល់ដីឈ្មោះ ដីឈ្មោះ[redacted] សន

+ខាងត្បូងទល់ដីឈ្មោះ [redacted] សាឯម

-ទី ៣ ដីភូមិ និង ដីចំការមានទំហំ ២០ម គុណ ៥០០ម មានព្រំប្រទល់

+ខាងកើតទល់នឹងទន្លេ

+ខាងកើតទល់នឹងដីប្រាំង

+ខាងជើងទល់ដីឈ្មោះ [redacted] ថារី

+ខាងត្បូងទល់ដីឈ្មោះ [redacted] ហួយ

ដីទាំងបីកន្លែងស្ថិតនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ។ អោយទៅចុងចម្លើយឈ្មោះ [redacted] សារ៉េត ប្រពន្ធឈ្មោះ [redacted] សុខឿន ចាប់ពីសាលក្រមចូលស្ថាពរតទៅ ។

៣-ប្រាក់ប្រដាប់ក្តីអោយដើមចោទជាអ្នកទទួល ។

-សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈចំពោះមុខគូភាគី មេធាវីតំណាងដោយអាណត្តិអោយដើមចោទ សំរេចនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ បើកសិទ្ធិអោយប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

*សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] ឈួន ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ០២ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល ។*

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៧ក្រVI"ជ"ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍សំរេច :**

១-ច្រានពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់ឈ្មោះ ញឹក ឈួន ចោល ។

២-រក្សាសាលក្រមរដ្ឋប្បវេណីលេខ ០៦"ក"រ.វចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការដដែល ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុកដើមចោទ ។

៤-សាលដីកានេះត្រូវប្រកាសជាសាធារណៈ នាថ្ងៃទី១១ ខែ តុលា ឆ្នាំ ២០១៣ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងអំឡុងពេល ០១ខែ គិតចាប់ពីពេលបានទទួលការបញ្ជូនសាលដីកានេះ ។

*សាលដីកានេះ ត្រូវបានឈ្មោះ [redacted] ឈួន ប្តឹងសាទុក្ខតាមបណ្តឹងលេខ ២១៤ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល ។*

**ខ-អំពីសេចក្តីថ្លែងការណ៍របស់គូភាគី :**

ឈ្មោះ [redacted] ឈួន ធ្វើសេចក្តីថ្លែងការណ៍ថា : ខ្លួនរស់នៅ និង ធ្វើស្រែចំការលើដីនេះ ៣០ឆ្នាំមក

២៤៨



Scanned with CamScanner

ហើយ តែមិនបានដាក់ពាក្យសុំកាន់កាប់ទេ ។ ឪពុកម្តាយខ្លួនបានធ្វើចំណាកស្រុកទៅរស់នៅខេត្តកោះកុងតាំងពីឆ្នាំ ២០០០ ក្រោយមកពេលចាស់ទ្រុឌទ្រោម បែរជាផ្ទេរមរតកអោយប្អូនខ្លួនតែម្នាក់ឯងទាំងអស់ ។ ដីនេះខ្លួនចូលកាន់កាប់តាំងពីឆ្នាំ១៩៨៤ មកជាមួយឪពុកម្តាយ ។ កាលឆ្នាំ៨៤ រដ្ឋបានចែកដីអោយខ្លួនដែរ តែដីទាំងនោះមានលក្ខណៈអោយកាប់រាន។

**សំណូមពរ :** សុំតុលាការសំរេចបែងចែកដីអោយខ្លួនមួយដែលជាកូនមួយចំណែកផង។

**ឈ្មោះ** [redacted] **សារ៉េត ធ្វើសេចក្តីថ្លែងការណ៍ថា :** ខ្លួនមិនយល់ព្រមតាមការលើកឡើងរបស់ដើម-ចោទទេ ។ កាលពីឆ្នាំ ១៩៨៤ រដ្ឋចែកដីអោយគាត់ស្មើនឹងឪពុកម្តាយដែរ ព្រោះគាត់មានគ្រួសាររួចហើយ។ ដោយឡែកប្រពន្ធខ្លួន និង ប្អូនពៅ នៅក្នុងបន្ទុកឪពុកម្តាយមានរបបជាមួយឪពុកម្តាយ ហេតុនេះទើបឪពុកម្តាយបែងចែកដីអោយប្រពន្ធខ្លួន និង ប្អូនពៅ តែបច្ចុប្បន្នប្អូនពៅបានលក់ចំណែកវាមកអោយខ្លួន និង ប្រពន្ធអស់ហើយ។ ដើមចោទគ្រាន់តែមកសុំរស់នៅបណ្តោះអាសន្នក្នុងឆ្នាំ ១៩៨៩ មិនមែន ១៩៨៤ទេ និង ជួលដីធ្វើ តែឈ្នួលក៏មិនដែលបាន ពេលខ្លួនជួលអោយទៅអ្នកផ្សេង គាត់ទៅដេញគេមិនអោយធ្វើ មិនតែប៉ុណ្ណោះថែមទាំងយកដីខ្លួនទៅដាក់បញ្ចាំអោយគេ ខ្លួនចេញលុយទៅតាមលោះយកដីមកវិញ។

**លោកស្រី** [redacted] **មេធាវីតំណាងដោយអាណត្តិអោយដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា :** កូនក្តីខ្លួនបានរស់នៅ និង ធ្វើស្រែចំការលើដីទាំង ៤កន្លែងតាំងពីឆ្នាំ ៨៤ មក ព្រោះឪពុកម្តាយចេញទៅនៅខេត្តកោះកុងតាំងពីឆ្នាំ ២០០០។ សូមពិនិត្យអំពីឯកសារផ្ទេរសិទ្ធិអោយកូនពីរនាក់ គឺចុងចម្លើយដាក់ពាក្យសុំកាន់កាប់មុនម្ចាស់ដីផ្ទេរសិទ្ធិអោយទៅទៀត។ នៅសាលាដំបូងកូនក្តីខ្លួនជាដើមបណ្តឹងទាមទារដីទាំង៤កន្លែង តែតុលាការសំរេចតែដី ៣កន្លែងទេ មិនតែប៉ុណ្ណោះ សំរេចយកទាំងដីចំណែកកូនក្តីខ្លួនទំហំ ២០ម គុណ ៤០ម អោយចុងចម្លើយទៀត។

ដូច្នេះ ក្នុងនាមកូនក្តីខ្លួនជាអ្នកថែរក្សា សុំតុលាការសំរេចបែងចែកដីអោយគាត់ ១ចំណែកដើម្បីភាពសមធម៌ និង យុត្តិធម៌អោយកូនក្តីខ្លួនផង។

**សំណូមពរ :** សុំបដិសេធចោលសាលដីកាសាលាឧទ្ធរណ៍ទាំងមូល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូក្តី និង សេចក្តីថ្លែងហេតុរបស់មេធាវីដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

# តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២១៤ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] ឈួន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពសាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលសាលាដំបូងខេត្តព្រៃវែង និង សាលាឧទ្ធរណ៍សំរេចច្រានចោលការទាមទារ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ របស់ឈ្មោះ [redacted] ឈួន ប្រពន្ធឈ្មោះ [redacted] ខេន និង សំរេចប្រគល់ដីស្រែប្រាំងទំហំ ១៩.៥០ម គុណ ៤០០ម , ដីចំការ(ដីឡូតិ៍) មានទំហំ ៨ម គុណ ៧០០ម , ដីភូមិប្លុកនឹងដីចំការទំហំ ២០ម គុណ ៥០០ម ស្ថិតនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង អោយទៅចុងចម្លើយឈ្មោះ [redacted] សារ៉េត និង ប្រពន្ធឈ្មោះ [redacted] សុខឿន នោះ ពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ពីព្រោះថា :-

ក-ទាំងសាលាដំបូង ទាំងសាលាឧទ្ធរណ៍ពិចារណាតែទៅលើលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ។

ខ-កិរិយានៃការកាន់កាប់របស់ភាគីដើមចោទ ដែលមានទីតាំងពីឆ្នាំ ១៩៨៤ ឬ ១៩៨៦ ហើយនឹងការអាក់ខានរបស់ឪពុកម្តាយគូភាគីតាំងពីឆ្នាំ ២០០០មក តុលាការទាំងពីរថ្នាក់មិនទាន់បានពិចារណាទេ ។

គ-ទំហំដីភាគីទាំងសងខាងអះអាងខុសគ្នា ។

-យល់ឃើញថា សាលដីការរដ្ឋប្បវេណីលេខ ២៧ ក្រ VI "ធ" ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះទាស់នឹងគតិច្បាប់ ។

## ហេតុដូចនេះ

## វិ និ ច្ឆ័ យ សេ ច ក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ២១៤ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] ឈួន ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ២៧ ក្រ VI "ធ" ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ២០៦ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។



Scanned with CamScanner

៤-ប្រាក់ប្រដាប់ក្ដីជាន់តុលាការកំពូលជាបន្ទុករបស់ភាគីចុងចម្លើយ ។

៥-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៤។

| | | |
|---|---|---|
| ឯកឧត្ដម | [redacted] | ប្រធាន |
| លោក | [redacted] | ចៅក្រម |
| លោក | [redacted] | ចៅក្រម |
| លោក | [redacted] | ចៅក្រម |
| លោក | [redacted] | ចៅក្រម |
| លោកស្រី | [redacted] | ក្រឡាបញ្ជី |

---

បានឃើញ
ភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤
ប្រធាន
[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner